# មេរៀនទី ២៥៖ រស់នៅដោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះ

រ៉ូម ៨៖៩-១៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/Wl186DyRjcs

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/CIloIKRXGK0

**គោលបំណង៖** ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយយើងទាំងអស់គ្នា

**ខគម្ពីរចងចាំ៖** រ៉ូម ៨៖១៤ *"អស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ពេលដែលព្រះវិញ្ញាណបរិសុទ្ធ https://youtu.be/RODHIMCRzw4
២. ខ្ញុំច្រៀងថ្វាយព្រះ https://youtu.be/1th9e8PKFxs
៣. ខ្ញុំថ្វាយបង្គំ https://youtu.be/1C4guXZFdAw

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត

សម្ភារៈដែលត្រូវការ៖ កែវ២ ទឹក អំបិល និងស្ករ

១. ចាក់ទឹកចូលក្នុងកែវ២នោះ។ ដាក់អំបិលក្នុងកែវមួយ ហើយនៅក្នុងកែវមួយទៀតដាក់ស្ករ




២. សួរកុមារថាតើពួកគេឃើញអ្វីប្លែកអំពីទឹកទាំង២កែវនេះ

៣. សុំឱ្យកុមារ ២នាក់ មកភ្លក់ទឹក និងឲ្យកុមារប្រាប់ពីរសជាតិទឹកដែលពួកគេបានភ្លក់រួច។

៤. ក្មេងដែលផឹកទឹកប្រៃនឹងនិយាយថា ទឹកនេះមិនមានរសជាតិឆ្ងាញ់ទេ។ កុមារដែលផឹកទឹកស្ករនឹង និយាយថាវាមានរសជាតិផ្អែម។

៥. សូមពន្យល់ដល់កុមារថា នៅពេលដែលព្រះវិញ្ញាណរបស់ព្រះគង់នៅក្នុងយើង មើលពីខាងក្រៅយើង ប្រហែលជាមើលទៅមិនខុសពីអ្នកដទៃនោះទេ ប៉ុន្តែនៅខាងក្នុងវិញវាពិតជាមានមានភាពខុសគ្នាយ៉ាងធំ។ ពេលយើងទុក ចិត្តលើព្រះយេស៊ូវ នោះព្រះវិញ្ញាណរបស់ព្រះធ្វើឲ្យជីវិតយើងផ្អែម!

## ៤. ការណែនាំមេរៀន

តើប្អូនអាចប្រាប់អ្នកគ្រូ/លោកគ្រូបានទេថានៅក្នុងខ្លួនរបស់ប្អូនមានអ្វីខ្លះ? (សូមឱ្យកុមារឆ្លើយ៖ បេះដូង សួត ឈាម សាច់ដុំ។ល។) តើប្អូនដឹងទេថាសំរាប់អ្នកជឿដល់ព្រះយេស៊ូវមានអ្វីម៉្យាងដែលនៅក្នុងខ្លួនពួកគេដែលអាចជួយ ពួកគេឲ្យក្លាយទៅជាគ្រិស្តបរិស័ទដ៏ល្អបាន តើប្អូនៗអាចទាយបានទេថាវាជាអ្វី? (ឲ្យកុមារឆ្លើយ)។ បាទ/ចាស នោះគឺជាព្រះវិញ្ញាណបរិសុទ្ធ។ បើទោះបីជាអ្នកមើលមិនឃើញ ដូចជាស្ករ ឬអំបិលក្នុងទឹកក៏ដោយ តែព្រះវិញ្ញាណរបស់ព្រះគង់នៅក្នុងយើងម្នាក់ៗ។ សូមឲ្យយើងបានគិតថា វាគឺជា

រឿងដ៏អស្ចារ្យណាស់-ព្រះអង្គដែលធំជាងលោកីយ៍ទាំងមូលបែរជាមកយកចិត្តទុកដាក់ចំពោះមនុស្សតូចៗ ដូចជាប្អូនៗ ហើយនឹងខ្ញុំដែរនោះ! មិនត្រឹមតែព្រះអង្គទ្រង់យកចិត្តទុកដាក់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់បានយាងមកគង់នៅក្នុងយើងថែមទៀតផង!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងព្រះគម្ពីរប៉ុលជាសាវកដ៏ស្មោះត្រង់ម្នាក់ ដែលបានសរសេរកណ្ឌគម្ពីរសញ្ញាថ្មីចំនួន ១៣ ក្នុងចំណោម ២៧ កណ្ឌក្នុងព្រះគម្ពីរ។ ថ្ងៃមួយគាត់បានគិតថា ហេតុអ្វីបានជាគាត់តែងតែជ្រើសរើសនូវជម្រើសដែលខុសនៅពេលដែលគាត់ពិតជាចង់ជ្រើសរើសនូវអ្វីដែលត្រឹមត្រូវអីចឹង។ បន្ទាប់មកគាត់ បានដឹងថា បើគ្រីស្ទបរិស័ទ ព្យាយាមធ្វើល្អដោយខ្លួនពួកគេ នោះពួកគេ នឹងបរាជ័យជានិច្ច។ ពួកគេនឹងឃើញថាខ្លួនឯង ជាមនុស្សគ្មាន មេត្តា ឈ្លើយ ច្រណែន អត្មានិយម លោភលន់ និងអ្វីៗជាច្រើនទៀត។

នៅក្នុងព្រះគម្ពីរ **រ៉ូម ជំពូក ៨** ប៉ុលពន្យល់យើងពីរបៀប ដែលព្រះជួយគ្រីស្ទបរិស័ទឱ្យធ្វើការជ្រើសរើសនូវជម្រើសដ៏ល្អមួយ។ ប៉ុលបង្រៀនថា ពេលយើងជឿលើព្រះយេស៊ូវ ទ្រង់ប្រទានអំណោយនៃព្រះវិញ្ញាណដល់យើង។ ព្រះគម្ពីរចែងថា ព្រះវិញ្ញាណបរិសុទ្ធជាអ្នកជំនួយអ្នកសម្រាលទុក្ខ និងជាគ្រូ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាដៃគូ ដ៏ខ្ជាប់ខ្ជួនរបស់យើងដែលផ្តល់ឱ្យយើងនូវក្តីសង្ឃឹម និងកម្លាំង។

ពេលយើងរស់នៅដោយព្រះវិញ្ញាណរបស់ព្រះ នោះយើងអាចងាកចេញពីអំពើបាប ហើយត្រូវបានសម្អាតពីអំពើបាបតាមរយៈការសុគតរបស់ព្រះយេស៊ូនៅលើឈើឆ្កាង។ លើសពីនេះ យើងក៏ត្រូវបានជ្រើសរើសជាកូនរបស់ព្រះផងដែរ! នៅក្នុងព្រះគម្ពីរ កូនចិញ្ចឹមមិនអន់ជាងកូនបង្កើតនោះទេ ពួកគេស្មើគ្នា។

ប៉ុលរីករាយដែលព្រះបានទទួលគាត់ជាកូនតាមរយៈជំនឿរបស់គាត់លើព្រះយេស៊ូវ។ ប៉ុលក៏បានដឹងដែរថា តាមរយៈព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងគាត់ គាត់អាចយកឈ្នះការល្បួងនៃអំពើបាប។ យើងអាចធ្វើបានដូចគាត់អីចឹងដែរ។ យើងគ្មានអំណាចធ្វើជាក្មេងប្រុសស្រីល្អទេ។ ប៉ុន្តែយើងមានព្រះវិញ្ញាណបរិសុទ្ធ ដែលតែងតែជួយយើងឲ្យធ្វើការជ្រើសរើសល្អ ហើយធ្វើជាគ្រីស្ទបរិស័ទដ៏ល្អបាន។

សូមគិតតាមបែបដូច្នេះ ព្រះជាអ្នកបង្កើតសកលលោកទាំងមូល ជាព្រះដែលមានបន្ទូលឲ្យកើត ពិភពលោកមក ហើយជាព្រះដែលគង់នៅក្នុងយើង! ពិតជាអស្ចារ្យណាស់! អ្វីដែលយើងត្រូវធ្វើគឺជឿ ហើយទុកចិត្តទ្រង់។ ក្នុងនាមជាកូនរបស់ព្រះ យើងអាចធានាបានថា ព្រះវិញ្ញាណរបស់ព្រះគង់នៅក្នុងយើង។

## ៦. សំនួរពិភាក្សា

១. តើនរណាមករស់នៅក្នុងយើងពេលយើងជឿលើព្រះ? *(ព្រះវិញ្ញាណបរិសុទ្ធ)*

២. តើព្រះវិញ្ញាណបរិសុទ្ធធ្វើអ្វីពេលទ្រង់មកគង់នៅក្នុងយើង ? *(ព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យមានចិត្តដូចព្រះ ហើយប្រទានឲ្យយើងនូវអំណាចដើម្បីប្រឆាំងនឹងការល្បួងនៃអំពើបាប)*

៣. តើនរណាខ្លះអាចទទួលបានព្រះវិញ្ញាណបរិសុទ្ធ? *(អស់អ្នកណាដែលជឿលើព្រះ ជាព្រះដែលបានចាត់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវឲ្យសុគតជំនួសអំពើបាបរបស់យើង ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីឲ្យយើងមានជីវិតអស់ កល្បនៅស្ថានសួគ៌)*

## ៧. ខគម្ពីរចងចាំ

**រ៉ូម ៨ៈ១៤** *"អស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ"*។

**៨. ហត្ថកម្ម**

សម្ភារៈដែលត្រូវការ៖ ចានក្រដាស កន្ត្រៃ ការ៉ ប៊ិក



១. ឱ្យចានក្រដាសទៅកុមារម្នាក់មួយ ហើយឱ្យពួកគេ គូររូបសត្វព្រាបនៅលើចាននៅចំកណ្តាល។

២. កាត់សងខាងធ្វើជាស្លាប ហើយកាត់តួខ្លួនព្រាបចេញ។

៣. យកការ៉បិទចុងទាំងសងខាងជាមួយគ្នា ដើម្បីធ្វើជាស្លាប។

៤. គូរភ្នែកលើក្បាលរបស់សត្វព្រាប។ យកការ៉បិទតួខ្លួនសត្វព្រាបនៅចំកណ្តាលស្លាប។

៥. នៅពេលណាដែលប្អូនឃើញសត្វព្រាបនេះ សូមចាំថាព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយប្អូនជានិច្ច!

**៩. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១០. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
សូមអធិស្ឋានថ្ងៃនេះ៖ «ព្រះជាម្ចាស់ទ្រង់បានធ្វើការ ដែលលើសពីការអត់ទោសឱ្យទូលបង្គំទៅទៀត។ ព្រះអង្គបានទទួលយកទូលបង្គំ។ ទូលបង្គំស្ទើរតែមិនជឿថាទ្រង់បានរាប់ទូលបង្គំជាកូនរបស់ទ្រង់នោះឡើយ។ សូមជួយទូលបង្គំឱ្យជឿថានេះជាការពិត ហើយឲ្យទូលបង្គំបានព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីរស់នៅជាមនុស្សថ្មី។ សូមពង្រឹងទូលបង្គំតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធថ្ងៃនេះ» ។ នៅពេលអ្នករៀបចំបង្រៀនក្មេងៗសូមចាំថាអ្នកមិននៅម្នាក់ឯងទេ ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយអ្នក។